# ស្ត្រីនិងសិទ្ធិស្ត្រី ក្នុងសាសនាឥស្លាម



## حقوق المرأة في الإسلام

لجنة كمبوديا وفيتنام ولاوس التابعة
لجمعية الدعوة والإرشاد وتوعية الجاليات
في حي الصحافة
الرياض - المملكة العربية السعودية

រៀបរៀងដោយ

## អង្គការវប្បធម៌ អារ្យធម៌កម្ពុជា អារ៉ាប់

## Cambodia Arab Cultural Civilizational Organization


*អំពីព័ត៌មានបន្ថែម:*

អាស័យដ្ឋានៈផ្ទះលេខ10អា ផ្លូវ បេតុង ភូមិទួលសំពៅ
សង្កាត់ ទួលសង្កែ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ
ប្រទេសកម្ពុជា

ទូរស័ព្ទលេខៈ+85577997733 , +855962336659

Email:Cacco818140@gmail.com

# សិទ្ធិស្ត្រីនៅក្នុងសាសនាឥស្លាម

☛គោរព

☛លើកកំពស់

☛ការពារ

មានអ្នកខ្លះគិតនិងរិះគន់ថា សិទ្ធិស្ត្រីនៅក្នុងសាសនាឥស្លាម ត្រូវបានគេបង្ក្រាប មិនឲ្យតម្លៃ និងមានការជិះជាន់។ តើកត្តាទាំងនេះពិតជាបានកើតឡើងដូចគេនិយាយដែរឬទេ? តើសាសនិកឥស្លាមរាប់រយលាននាក់ពិតជាមានការរំលោភសិទ្ធិ ឬមួយក៏ទស្សនៈយល់ច្រឡំ ខាងលើទាំងនេះត្រូវបានប្រឌិតឡើងដោយ ប្រព័ន្ធពត៌មានដែលមានភាពលំអៀងខុសការពិត?ព្រះ(អល់ឡោះ) បានមានព្រះបន្ទូលថា " ហើយសម្រាប់ស្ត្រីមានសិទ្ធិទៅលើបុរស ដូច(សិទ្ធិ)បុរសមានមកលើស្ត្រី"(អាល់គួរអាន)(2:228)។ តាមពិត សាសនាឥស្លាមបានផ្ត-ល់ សិទ្ធិឲ្យស្ត្រីអស់

រយៈពេលជាង១៤០០ឆ្នាំមកហើយ តែស្ត្រីនៅក្នុងបណ្តាប្រទេសលោកខាងលិចវិញទើបតទទួលបានសិទ្ធិរបស់ខ្លួន នាពេលថ្មីៗនេះតែប៉ុនណោះ។ នៅក្នុងអំឡុងទសវត្សរ៍៣០(1930's) អ្នកស្រី អានី បីសាន់ត៍ (Annie Besant)ជាអ្នកសង្គមនិយមអង់គ្លេសដ៏ខ្ពង់ខ្ពស់ម្នាក់ និងជាសកម្មជនទាមទារ សិទ្ធិស្ត្រីយ៉ាងសកម្មម្នាក់បានសង្កេតឃើញថា" រដ្ឋាភិបាលនៃចក្រភពអង់គ្លេស ទើបតែទទួលស្គាល់សិទ្ធិស្ត្រីទៅលើការគ្រប់គ្រងទ្រព្យសម្បត្តិ នារយៈពេល២០ឆ្នាំថ្មីៗចុងក្រោយនេះទេ រីឯសម្រាប់សាសនាឥស្លាមវិញ បានផ្តល់ឲ្យសិទ្ធិស្ត្រីនេះ អស់រយៈពេលជាយូរយាណាស់មកហើយ(១៤០០ឆ្នាំមុន)"។លោកស្រីក៏បន្តទៀតថា វាជាការនិយាយ បង្ខូចកេរ្តិ៍ឈ្មោះសាសនាឥស្លាម ពិតៗចំពោះអ្នកដែលនិយាយ ថាសាសនាឥស្លាមអបរំថាស្ត្រីគ្មានសិទ្ធិអ្វីទាំងអស់។ ដូចនឹងអ្វីដែលសៀវភៅមួយ

បានចេញផ្សាយក្នុងឆ្នាំ១៩៣២ ដែលមានចំណងជើងថា"The life and Teachings of Mohammad,1932"។

នៅក្នុងសាសនាឥស្លាម ទទួលស្គាល់ថា បុរស និងស្ត្រី (មនុស្សជាតិ)ទាំងអស់មានប្រភពពង្សាវតា ចេញមកពីបុរសតែម្នាក់ដូចតែគ្នា គឺព្យាការីអាដាំ(សូមសន្តិភាពកើតមានមកដល់គាត់)។ ឥស្លាមមិនអាចទទួលយកបានឡើយចំពោះ សំដីគ្មានការពិតខាងលើ ខុសពីប្រភពឥស្លម តែសាសនាឥស្លាមនៅតែប្រកាន់ភាពយុត្តិធម៌ និង អប់រំមនុស្សឲ្យធ្វើអំពើល្អតាមគោលការណ៍របស់ខ្លួន។

**គោលការណ៍គណនេយ្យភាពនិងការតបស្នងស្មើគ្នា**

បុរស និង ស្ត្រី គោរពសក្ការៈចំពោះព្រះ( អល់ឡោះ) នៅក្នុងផ្លូវតែមួយដូចគ្នា មានន័យថា ពួកគេទាំងអស់ គ្នាគោរពព្រះ (អល់ឡោះ) តែមួយដូច

គ្នា, មានសកម្មភាពនៃការធ្វើសក្ការ: (worship) ដូចគ្នា អនុវត្តតាមគម្ពីរគួរអានដូចគ្នា និង មានជំនឿដូចគ្នា ។ សាលក្រមឬក៏ការកាត់ក្ដីរបស់ព្រះ (អល់ឡោះ) ពិតជាប្រកបដោយភាពយុត្តិធម៌ និង ភាពសមធម៌ជាទីបំផុតចំពោះមនុស្សលោក (នៅថ្ងៃបរលោក)។ អល់ឡោះ(ភាសាអារ៉ាប់មានន័យថាព្រះ) បានសង្កត់ធ្ងន់អំពីភាព យុត្តិធម៌និងការតបស្នង (អំពើកុសលឬអកុសល)មានជាច្រើននៅក្នុងគម្ពីគួរអាន។

- ព្រះ (អល់ឡោះ) បានសន្យា ចំពោះបណ្ដាអ្នកមានជំនឿ ទាំងប្រុទាំងស្រីនូវស្ថានសួគ៌ដែលមានទន្លេជាច្រើនហូរកាត់ពីក្រោមវា ដោយពួកគេស្ថិតនៅក្នុងវាជាអមតៈ និងមានភូមិគ្រឹះ ជាច្រើនដ៏ប្រណីតនៅក្នុងឋានសួគ៌អមតៈបរមសុខ(គួរអាន9:72)។
- យើងពិតជានឹង មិនបំបាត់រាល់ទង្វើដែលពួកអ្នកបាន ធ្វើក្នុងចំណោមពួកអ្នកឡើយ ទោះបីជាបុរស

ក្តី ឬស្រ្តីក្តី ពីព្រោះពួកអ្នកចេញមកពីអំបូរតែមួយ(គួរអាន3:195)។

ពាក្យសំដីខ្លះៗរបស់ព្រះ (អល់ឡោះ)ខាងលើចង់បង្ហាញថា ការតបស្នងរបស់ព្រះជាម្ចាស់ គឺផ្តោតសំខាន់លើសកម្មភាពរបស់បុគ្គល ម្នាក់ៗជារឿងសំខាន់ តែមិនបានចាត់ទុកភេទ(ស្រីឬប្រុស)ជាចំនុចសំខាន់នោះទេ។ ភេទ មិនមានតួនាទីសំខាន់លើការទទួល ការវិនិច្ឆ័យក្តីឬការតបស្នងពីព្រះ(អល់ឡោះ) នោះឡើយ។ប្រសិនជាយើង យកសាសនាឥស្លាមមកប្រៀបធៀប ជាមួយសាសនាផ្សេងៗទៀត យើងនឹងឃើញថាសាសនាឥស្លាម បានផ្តល់ភាពយុត្តិធម៌អំពីសិទ្ធិរៀងៗខ្លួន រវាងបុរសនិងស្រ្តីជាងគេបំផុត។ ឥស្លាមមិនព្រមទទួលយកបានឡើយ នូវទស្សនៈថានាងអេវ៉ាត្រូវបានស្តីបន្ទោសច្រើនជាង អាដាំ ដោយសារតែការបរិភោគផ្លែឈើ ដែលព្រះបានហាម

ឃាត់។ យោងទៅតាមទស្សនៈឥស្លាមវិញ គេទាំងពីរ អាដាំនិងនាងអេវ៉ាបានប្រព្រឹត្តអំពើបាបដូចគ្នា,ក្រោយមកពួកគេទាំងពីរ ក៏បានសុំអភ័យទោសចំពោះព្រជាម្ចាស់ ហើយទ្រង់(អល់ឡោះ)ក៏លើកលែងទោសឲ្យពួកគេទាំងពីរផងដែរ។

## *សិទ្ធិស្មើគ្នាក្នុងការអប់រំ*

បុរសនិងស្ត្រីត្រូវបានឥស្លាមជម្រុញឲ្យទទួលការអប់រំស្មើៗគ្នា។ ព្យាការីមូហាំម៉ាត់(សូមសន្តិភាពមកដល់គាត់) បានមានប្រសាសន៍ថា "ការអប់រំ គឺជាកាតព្វកិច្ចសម្រាប់សាសនិកឥស្លាមទូទៅ (ប្រុសស្រីចាស់ក្មេង)"។ទន្ទឹមនិងនោះ នាសម័យកាលព្យាការីមានស្ត្រី ជាច្រើនបានទទួលការអប់រំរហូតក្លាយជាបណ្ឌិតឬអ្នកប្រាជ្ញផ្នែកសាសនាឥស្លាម។ ស្ត្រីខ្លះក្នុងចំណោមទាំងនោះ ជាមនុស្សក្នុងគ្រួសាររបស់ព្យាការី

ហើយអ្នកខ្លះជាអ្នកនៅជុំវិញគាត់ និង អ្នកខ្លះផ្សេងទៀត ជាជាកូនស្រីរបស់បណ្តាមិត្តភក្តិរបស់គាត់(ព្យាការី)។ ក្នុងចំណោមអ្នកដែលទទួលបានការអប់រំខ្ពង់ខ្ពស់ ទាំងអស់នោះមានដូចជានាងអាអ៊ីសះជាដើមដែលជាភរិយារបស់ព្យាការីរបស់យើង។ ជាពិសេសមួយភាគបួន(1/4) នៃប្រភពច្បាប់ឥស្លាមទាំងមូលត្រូវបានដកស្រង់ចំលងចេញពីនាងអាអ៊ីសះ។ មានស្ត្រីឥស្លាមខ្លះទៀត គឺបានក្លាយជាបណ្ឌិតអ្នកប្រាជ្ញផ្នែកសាសនាឥស្លាម និងមានបណ្ឌិតអ្នកប្រាជ្ញល្បីល្បាញផ្នែកបុរសជាច្រើន បានធ្លាប់ទទួលការអប់រំពីស្ត្រីបណ្ឌិតទាំងអស់នោះដែរ។

## សិទ្ធិស្មើគ្នាក្នុងការជ្រើសរើសគូជីវិត

ឥស្លាមបានលើកកំពស់សិទ្ធិស្ត្រី ដោយផ្តល់សិទ្ធិឲ្យស្ត្រីទូទៅ ដែលគ្រប់អាយុមានសិទ្ធិជ្រើសរើសគូជីវិត និង រក្សានាមត្រកូលរបស់ខ្លួនឲ្យនៅគង់វង្សក្រោយពី

រៀបការរួច។

មនុស្សមួយចំនួនធំដែលបាន មានទស្សនៈថា ស្ត្រីឥស្លាមត្រូវបានបង្ខិតបង្ខំដោយឪពុកម្តាយ ឬ អាណាព្យាបាលក្នុង ការរៀបអាពាហ៍

ហ៍ពិពាហ៍របស់ខ្លួន។ រឿងជាក់ស្តែង ការបង្ខិតបង្ខំទាំងអស់នោះ គ្រាន់តែជាទំនៀមទំលាប់ ប្រពៃណីរបស់ក្រុមគ្រួសារណាមួយ ឬក្រុមជាតិសាសន៍ណាមួយប៉ុណ្ណោះ។ តាមការពិត សាសនាឥស្លាម បានហាមឃាត់យ៉ាងដាច់ខាតរាល់ អំពើបង្ខិតបង្ខំទាំងឡាយនោះ។

នាសម័យកាលព្យាការី មានស្ត្រីម្នាក់បានរត់មកប្រាប់ព្យាការីថា "ឪពុករបស់ខ្ញុំបានបង្ខំខ្ញុំឲ្យរៀបការនិងបុរសម្នាក់ដែលត្រូវជាជីដូនមួយរបស់ខ្ញុំ ដោយសារឪពុករបស់ខ្ញុំចង់បានឡើងសក្តិខ្ពស់"។ ដឹងដូច្នោះព្យាការីក៏បានផ្ញើលិខិត ទៅឲ្យបុរសជាឪពុកនោះ ដោយ

បញ្ជាក់ថា ចូរឲ្យនាងមានជម្រើសនៅក្នុងការរៀបការ បើមិនដូច្នោះទេអាពាហ៍ពិពាហ៍នោះត្រូវចាត់ទុកជាមោឃៈ។ ក្រោយបន្តិចមក នាងក៏បានមកប្រាប់ព្យាការីថា "ឱព្យាការីរបស់ព្រះ(អល់ឡោះ)ពេលនេះ ឪពុកខ្ញុំបានទទួលនិង ការឆ្លើយតបរបស់ខ្ញុំហើយ ហើយខ្ញុំក៏ចង់បង្ហាញឲ្យស្រីៗផ្សេងទៀតដឹង (ថាគ្មានអ្នកណាម្នាក់មានសិទ្ធិបង្ខំមនុស្សស្រីក្នុងការរៀបអាពាហ៍ពិពាហ៍នៅក្នុងសាសនាឥស្លាមឡើយ)"។

## សិទ្ធិស្មើគ្នា តែខុសគ្នា

បុរសនិងស្ត្រីមានសិទ្ធិស្មើៗគ្នា តាមគោលការណ៍ទូទៅ រីឯសិទ្ធិពិសេសនិងភាពទំនួលខុសត្រូវមួយចំនួនមិនបានផ្ដល់និង ការឆ្លើយតបដូចគ្នាបិះបិទបានទេ។ បុរសនិងស្ត្រីមានសិទ្ធិ និង ទំនួលខុសត្រូវពេញលេញដូចគ្នា។ ដោយសារភាពខុគ្នាដោយកាយវិភាគសាស្ត្រនៃផ្នែកខាងក្នុង និងផ្នែកខាងក្រៅរវាង

បុរសនិងស្ត្រី អ្នកវិទ្យាសាស្ត្របានរកឃើញថា មានភាពខុសគ្នា ជាច្រើននៃភាពឆ្លាតវៃយនៅក្នុង ខួរក្បាលរបស់មនុស្សប្រុសនិង មនុស្សស្រីក្នុងការរៀនភាសា ឆាប់ទទួលបានពត៌មាន និងឆាប់ទទួលការរំភើប។ អ្នកជំនាញឯកទេសផ្នែកជីវសាស្ត្រសង្គម លោក អិដវដ អូ វិលសុន (Edward O. Wilson) មកពីសកលវិទ្យាល័យហាវើត (Harvard University) បានមានប្រសាសន៍ថា មនុស្សស្រីមានលក្ខណៈខ្ពស់ជាងមនុស្សប្រុសក្នុងជំនាញផ្នែកនិយាយ ជំនាញផ្នែកសង្គម និងការឆាប់យល់ចិត្ត។ ផ្សេងពីនោះវិញ មនុស្សប្រុសមានលក្ខណៈខ្ពស់ ជាងមនុស្សស្រីក្នុងភាពម្ចាស់ការខ្លួនឯង ការគ្រប់គ្រង និងភាពជំនាញខាងផ្នែកលំហ និង ផ្នែកគណិតវិទ្យា និងទាក់ទង និងសកម្មភាពរំលោភបំពានគេ ព្រមទាំងចរិកលក្ខណៈផ្សេងៗទៀត។

- ព្រះ(អល់ឡោះ) មានព្រះបន្ទូលថា″ ហើយមនុស្សប្រុស មិន ដូចជាមនុស្សស្រីទេ″(គួរអាន 3:36)។

‶តើម្ចាស់ដែលបង្កើត(អ្វីៗទាំងអស់)មិនបានដឹងទេឬ? ហើយទ្រង់គឺជាអ្នកដែល

- មហាទន់ភ្លន់ និង ជ្រួតជ្រាបបំផុត″(គួរអាន67:14)។

### *ក្រុមគ្រួសា*

ព្រះ(អល់ឡោះ) បានបង្កើតមនុស្សប្រុសនិងមនុស្សស្រី នៅក្នុងពិភពលោកនេះ មានភាពខុសៗគ្នាទាំងតួនាទីឬមុខងារ ទំនួលខុសត្រូវ និង ជំនាញរបស់ខ្លួន(បុរសនិងស្ត្រី)រៀងៗខ្លួន។ ភាពខុសៗគ្នាទាំងអស់នេះ មិនមែនជាភស្តុតាងដាក់បន្ទុកថា មានភាពខ្ពស់ជាងគ្នាឬទាបជាងគ្នានោះទេ ប៉ុន្តែភាពខ្ពស់ជាង

ឬ ទាបជាងគ្នានេះគឺដើម្បីឲ្យមនុស្សប្រុសឬស្រីទាំងនោះ ប្រើប្រាស់ឲ្យត្រឹមត្រូវសមស្របនិងជំនាញឯកទេស ដែលខ្លួនមានរៀងៗខ្លួនតាមព្រះបានប្រទានអោយខុសៗគ្នាក្នុងនាមជា មនុស្សប្រុសឬមនុស្សស្រី។នៅក្នុងសាសនាឥស្លាម គ្រួសាត្រូវបានចាត់ទុកជារឿងសំខាន់បំផុត។ បុរសមានតួនាទីសំខាន់ ក្នុងការទទួលខុសត្រូវសុខុមាលភាពផ្នែកហិរញ្ញវត្ថុ ឲ្យបានប្រសើរសម្រាប់គ្រួសាររបស់ខ្លួន រីឯ ស្ត្រីវិញគឺមានតួនាទីចាត់ចែងរៀបចំ គ្រួសារឲ្យបានល្អទាំងសីលធម៌និងការអប់រំ។ នេះ ជម្រុញឲ្យមានភាពសហការគ្នា។ ជាលទ្ធផល ការសហការគ្នានិងនាំឲ្យមានភាពរីកចម្រើនល្អប្រសើរ ច្រើនលើសពីការប្រកួតប្រជែងគ្នាទៅទៀត។ ដោយការបំពេញបាន នូវទំនួលខុសត្រូវទាំងសងខាងរៀងៗខ្លួន( បុរស និង ស្ត្រីនៅក្នុងគ្រួសារ) ជាលទ្ធផលវាធ្វើឲ្យគ្រួសារទាំងនោះមានភាពរឹងមាំ និងនាំឲ្យ

សង្គមទាំងមូលមានភាពរឹងមាំដូចគ្នា។ ជាទូទៅបុរស និងស្ត្រីមិនអាចទទួលបាន សុភមង្គលបានឡើយ ដរាបណាបុរសឬស្ត្រី មិនបានបំពេញភាពខ្វះខាតឲ្យគ្នាទៅវិញទៅមកនោះ។ អល់ឡោះបានមានព្រះបន្ទូលថា "ពួកនាង(ភរិយា)ជាសំលៀកបំពាក់សម្រាប់ពួកអ្នក ហើយពួកអ្នក(ស្វាមី)ជា សំលៀកបំពាក់សម្រាប់ពួកនាង"(គួរអាន2:187)។ សំលៀកបំពាក់សម្រាប់គ្នាទៅវិញទៅមក ចំនុចនេះចង់មានន័យថា គឺបំពេញភាពខ្វះខាតឲ្យគ្នាទៅវិញទៅមក ដើម្បី ផ្តល់ឲ្យមានភាពងាយស្រួល ភាពកក់ក្តៅ និងសន្តិសុខ ហើយធ្វើឲ្យលេចឡើងនូវភាព ល្អប្រសើរចំពោះគ្នាទៅវិញទៅមកផងដែរ។ នេះហើយ គឺជាអត្ថន័យនៃទំនាក់ទំនងរវាង ពាក្យថាប្តីប្រពន្ធនៅក្នុងសាសនាឥស្លាម។

## *សេចក្ដីស្រលាញ់និងការអាណិតនៅក្នុងទំនាក់ទំនងស្វាមីនិងភរិយា*

ព្យាការី (សូមសន្តិភាពមកដល់គាត់)បានជម្រុញស្វាមី និង ភរិយាឲ្យគោរពសិទ្ធិគ្នាទៅវិញទៅមកឲ្យបាន ល្អប្រសើរបំផុត។ ព្យាការីបានមានប្រសាសន៍ថា "អ្នកដែលល្អបំផុតគឺជាអ្នកដែល ល្អបំផុតចំពោះភរិយារបស់ពួកគេ"។ មានពេលមួយ គេបានសួរអាអ៊ីសះជាភរិយារបស់ព្យាការី អំពីសកម្មភាពព្យាការីនៅក្នុងផ្ទះ។ អាអ៊ីសាក៏បានឆ្លើយថា "នៅផ្ទះ គាត់ក៏ដូចជាអ្នកទាំងអស់គ្នាដែរ តែគាត់ជាមនុស្សអត់អោននិងចិត្តល្អបំផុត...គាត់ត្រៀមជួយបណ្ដា ភរិយារបស់គាត់រួចជាស្រេចទោះជានៅក្នុងការងារផ្ទះ ដ៏សាមញ្ញៗក៏ដោយគាត់បានដេរប៉ាក់ខោអាវគាត់ និងបានជួសជុលស្បែកជើងរបស់គាត់ដោយខ្លួនឯង"។ ជាទូទៅគាត់បានជួយរាល់ការងារណាដែលបណ្ដាភរិយារបស់គាត់ធ្វើ។

# តួនាទីចម្បងនៃមាតានិងបុត្រាបុត្រី

ម្តាយពិតជា មានឥទ្ធិពលខ្លាំងបំផុតមកលើកូនៗរបស់ខ្លួន ។ កូនៗបានទទួលឥទ្ធិពលពីម្តាយរបស់ខ្លួនតាំងពីកុមារភាពមកម្ល៉េះតាមរយៈសេចក្តីស្រលាញ់និងការថែទាំ។គ្មានអ្វីគួរឲ្យងឿងឆ្ងល់នោះទេដោគជ័យនៃសង្គមដោយសារតែម្តាយ។ ដូច្នេះហើយ បានជាសាសនាឥស្លាម បានគោរពនិងលើកកំពស់តួនាទីរបស់មាតា។ ជាឧទាហរណ៍ព្រះ(អល់ឡោះ)បានមានព្រះបន្ទូលថា "ហើយយើងបានដាក់បទបញ្ញាឲ្យមនុស្សជាតិធ្វើល្អចំពោះឪពុកម្តាយរបស់គេ។ ម្តាយរបស់គេបានពរពោះពួកគេ ដោយលំបាកនិងបានប្រសូតគេមកយ៉ាងលំបាកវេទនា" (គួរអាន46:15)។

មានពេលមួយ គេបានសួរព្យាការី(សូមសន្តិភាពមកដល់គាត់) ថា ឱព្យាការីរបស់ ព្រះជាម្ចាស់ តើអ្នកណាម្នាក់ក្នុងចំណោមមនុស្សលោក ទាំងអស់

ដែលខ្ញុំត្រូវធ្វើល្អបំផុតចំពោះគាត់ជាងគេនោះ? ព្យាការីក៏បានឆ្លើយថា" **គឺម្តាយរបស់អ្នក** "។ បុរសនោះសួរបានពីរដង ហើយ ក៏នៅតែសួរបន្តទៀត ចុះបន្ទាប់មកអ្នកណាទៀត? ចម្លើយនៅតែដដែល(គឺម្តាយរបស់អ្នក) រហូតសំនួរដដែលនេះសួរលើកទីបួន ទើបព្យាការីបានឆ្លើយប្រាប់ថា:"បន្ទាប់មកគឺឪពុករបស់អ្នក"។ ព្រះជាម្ចាស់មិន ត្រឹមតែផ្តល់រង្វាន់សម្រាប់តែការប្រព្រឹត្តអំពើល្អទូទៅ និង ការធ្វើល្អចំពោះម្តាយប៉ុណ្ណោះទេ តែសាសនាឥស្លាមបានកំណត់ផ្តល់ជូនរង្វាន់ ពិសេសបន្ថែមសម្រាប់ការចិញ្ចឹមកូនស្រី ហើយដែលរង្វាន់ពិសេសនេះគ្មានទេធានាផ្តល់ជូនសម្រាប់ចិញ្ចឹមកូនប្រុស។

# សេចក្ដីបញ្ចប់

នៅក្នុងសង្គមអារ៉ាប់ មុនសាសនាឥស្លាមមក ដល់មុនឆ្នាំ៦២២គស ស្ត្រីមិនត្រូវបានគេឲ្យតម្លៃ កូនស្រីតូចៗត្រូវបានគេកប់ទាំងរស់ ពេស្យាចារ្យព្រោងព្រៀត សិទ្ធិនៃការលែងលះគ្នាស្ថិតលើប្ដីតែមួយគត់ ទ្រព្យមរតកសម្រាប់តែអ្នកខ្លាំងប៉ុណ្ណោះ និងអំពើជិះជាន់មាននៅគ្រប់ទីកន្លែង។ នៅពេលសាសនាឥស្លាមបានមកដល់ អំពើយង់ឃ្នង ព្រៃផ្សៃ និងភាពអយុត្តិធម៌ផ្សេងៗដែលបានរៀបរាប់ខ្លះៗខាងលើនេះត្រូវបានរលាយសាបសូន្យអស់។ ទោះបីជាចូលមកដល់សម័យកាល ដ៏ទំនើបបច្ចុប្បន្ននេះទៅហើយ នៅក្នុងប្រទេសអភិវឌ្ឍន៍ ឬ ប្រទេសជឿនលឿនផ្សេងៗទៀត នៅតែមិនទាន់គោរព លើកកំពស់សិទ្ធិស្ត្រី រហូតដល់បង្ខំឬឲ្យស្ត្រីធ្វើការពេញម៉ោង ពេញកំលាំងនូវការងារមនុស្សប្រុស ឲ្យស្មើគ្នានិងបុរសដែរ។ នៅក្នុង

សាសនាឥស្លាម បានទទួលស្គាល់សិទ្ធិស្ត្រីនិងលើកតម្កើងស្ត្រី ឲ្យមានតម្លៃខ្ពង់ខ្ពស់ដូចជាវត្ថុកម្រមួយដែលមានតម្លៃខ្ពស់បំផុត ។ ការប្រព្រឹត្តទៅនៃភាពមិនប្រក្រតីទៅលើស្ត្រី នៅក្នុងប្រទេសខ្លះ នៅក្នុងមជ្ឈឹមបូព៌ា គឺកើតឡើងដោយសារតែកត្តាវប្បធម៌ គ្រួសាររបស់សាសនិកឥស្លាមខ្លះតែប៉ុណ្ណោះ។ ធាតុពិតអំពើមិនប្រក្រតី លើស្ត្រីឬការមិនគោរពសិទ្ធិស្ត្រី គឺច្បាប់ឥស្លាមបានហាមឃាត់យ៉ាងដាច់ខាត។ យើងអាចធ្វើការស្រាវជ្រាវ និង វិភាគឲ្យល្អិតល្អន់ដោយខ្លួនឯងថា ប្រសិនបើ សាសនាឥស្លាមពិតជាបំបិទសិទ្ធិស្ត្រីពិតមែននោះ ហេតុអ្វីបានជាស្ត្រីមិនមែនឥស្លាមជាច្រើននៅក្នុងពិភពលោក ជាពិសេសស្ត្រីនៅក្នុងបណ្តាប្រទេសលោកខាងលិច សម្រេចចិត្តចូលសាសនាឥស្លាម មានចំនួនច្រើនកុះករជារៀងរាល់ថ្ងៃដូច្នេះ? យើងគួរដាក់សំនួរសួរខ្លួនឯងម្តងទៀតថាៈ តើប្រទេស

អភិវឌ្ឍខ្លះពិតជាគោរពសិទ្ធិស្ត្រី និង លើកកំពស់ភាពថ្លៃថ្នូររបស់ស្ត្រីមែនឬ? សង្គមវប្បធម៌របស់ប្រទេសជឿនលឿន ឬ ប្រទេសអភិវឌ្ឍន៍ខ្លះ កំពុងតែប្រកាសអះអាងប្រាប់ពិភពលោកថា ខ្លួនជាអ្នកបង្កើតសិទ្ធិស្ត្រី និងជាអ្នកគោរពសិទ្ធិស្ត្រី តែធាតុពិតខ្លួនជាអ្នកបំផ្លាញតម្លៃឬភាព ថ្លៃថ្នូររបស់ស្ត្រី និងមើលងាយរូបសម្បត្តិស្ត្រីតាមរូបភាពផ្សេងៗទៅវិញ។

ជាចុងក្រោយនេះ ខ្ញុំសូមធ្វើសេចក្តីបញ្ចប់ជាមួយ និង ព្រះបន្ទូរបស់ព្រះ (អល់ឡោះ) ជាម្ចាស់របស់ខ្ញុំ និងជាម្ចាស់របស់អ្នកដែរនោះជាមួយនិងពាក្យសំដីដូចតទៅ "ពិតប្រាកដណាស់ បណ្តាមូស្លីមប្រុសស្រី និង បណ្តាអ្នក មានជំនឿប្រុសស្រី និងបណ្តាអ្នកគោរពប្រតិបត្តិប្រុសស្រី និង បណ្តាអ្នកសច្ចៈប្រុសស្រី និង បណ្តាអ្នកដែលអត់ធ្មត់ប្រុសស្រី និង បណ្តាអ្នកឱនលំទោនប្រុសស្រី និងបណ្តាអ្នកបរិច្ចាគទានប្រុសស្រី

និងបណ្ដាអ្នកបួសប្រុសស្រី និងបណ្ដាអ្នកដែលរក្សាកេរ្ដិ៍ខ្មាស់របស់ ពួកគេទាំងប្រុសទាំងស្រី ហើយនិងបណ្ដាអ្នកដែលរំលឹកចំពោះ អល់ឡោះយ៉ាងច្រើនទាំងប្រុសទាំងស្រី អល់ឡោះបានរៀបចំ សម្រាប់ពួកគេនូវការអភ័យទោសនិងផលបុណ្យដ៏ធំធេង(ឋានសួគ៌)។"
(គួរអាន33:35)។

# សម្រាប់រាល់ឯកសារបន្ថែមអំពីឥស្លាម:

- អាចជជែក(chat)តាមអនឡាញ:www.islamtomorrow.com/
- ទាញយកជាវីឌីអូ : www.thedeenshow.com
- ទាញជសៀវភៅ:www.islamicmessage.net/cims/default.aspx
- អំពីព្យាការីមូហាំម៉ាត់:www.rasoulallah.net

# ព្យាការីមូ៉ហាំម៉ាត់បានមានប្រសាសន៍ថា ចូរពួកអ្នកផ្ដែផ្ដាំគ្នា ឱ្យធ្វើល្អចំពោះស្ដ្រីភេទ

لجنة كمبوديا وفيتنام ولاوس التابعة
لجمعية الدعوة والإرشاد وتوعية الجاليات
في حي الصحافة
الرياض - المملكة العربية السعودية